-ធ្វើរបាយការណ៍អំពីវិធានការដែលពាក់ព័ន្ធនឹងការចូលរួមនៃការងារកែទម្រង់រាជរដ្ឋាភិបាល ។

ប្រការ ៣ ៖ សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងសាមីខ្លួន ដែលមានចែងឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

ភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ៦៨ សសរ**

**ស្តីពីការ បើកផ្តល់បរិញ្ញាប័ត្រគ្រប់មុខវិជ្ជាសិក្សា**

**តាមប្រព័ន្ធបង់ថ្លៃនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

ប្រការ ១ ៖ អនុញ្ញាតអោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បើកផ្តល់បរិញ្ញាប័ត្រ សិក្សាតាមប្រព័ន្ធបង់ថ្លៃចាប់ពីឆ្នាំសិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។

ប្រការ ២ : ផ្នែកសិក្សាដែលត្រូវបើកមាន :

ក-មហាវិទ្យាល័យអក្សរសាស្ត្រ- មនុស្សសាស្ត្រ

-ផ្នែកអក្សរសាស្ត្រ ផ្នែកទស្សនវិជ្ជា

-ផ្នែកប្រវត្តិវិទ្យា ផ្នែកចិត្តវិទ្យា

-ផ្នែកសង្គមវិទ្យា ផ្នែកភូមិវិទ្យា

ខ-មហាវិទ្យាល័យវិទ្យាសាស្ត្រ

-ផ្នែកគណិតវិទ្យា ផ្នែកជីវវិទ្យា

-ផ្នែករូបវិទ្យា ផ្នែកព័ត៌មានវិទ្យា

-ផ្នែកគីមី ផ្នែកគ្រប់គ្រងធនធានធម្មជាតិ

គ-វិទ្យាស្ថានភាសាបរទេស

-ផ្នែកភាសាអង់គ្លេស និង វិជ្ជាជីវៈ

-ផ្នែកភាសាបារាំង និង វិជ្ជាជីវៈ

ប្រការ ៣ : លក្ខខណ្ឌចូលសិក្សា :

ជនគ្រប់រូបដែលមាន :

-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលគេទទួលស្គាល់ថាស្មើ ។

-បានប្រឡងជាប់ក្នុងការប្រលងជ្រើសរើស

ប្រការ ៤ : ថ្នាក់បរិញ្ញាបត្រមានរយៈពេលសិក្សា ៤ ឆ្នាំ ។

- និស្សិតដែលបានរៀនមុខជំនាញរួចហើយ នៅតាមមហាវិទ្យាល័យនានាអាចផ្ទេរការសិក្សាចូលរៀនថ្នាក់បង់ថ្លៃនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងករណីមិនប្រព្រឹត្តផ្លាស់ប្តូរជំនាញដែលគេមិនធ្លាប់រៀនពីមុន ។
- ប្រព័ន្ធសិក្សាបង់ថ្លៃ និងប្រព័ន្ធសិក្សាឥតបង់ថ្លៃមិនអាចផ្ទេរគ្នាទៅវិញទៅមកបានទេ ។
- ចុងបញ្ចប់នៃថ្នាក់សិក្សានីមួយៗ និស្សិតត្រូវធ្វើការប្រឡងបញ្ចប់គ្រប់មុខវិជ្ជា ដែលមាននៅក្នុងកម្មវិធីប្រកបដោយជោគជ័យ ។

ប្រការ ៥ : ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតក្រុមប្រឹក្សាភិបាលមួយ ដើម្បីទទួលខុសត្រូវលើផ្នែកសិក្សា រដ្ឋបាល និង ហិរញ្ញវត្ថុ និងត្រូវធ្វើបទបញ្ជាផ្សេងៗ ដើម្បីគ្រប់គ្រងថ្នាក់ទាំងអស់នេះ អោយដំណើរការបានល្អ និងមានគុណភាព ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ នឹងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៨ : សេចក្តីសំរេចនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៦៩ សសរ

## ស្តីពីការបង្កើតគណៈកម្មការដោះស្រាយបាតុភាពនៅក្នុងតំបន់ ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និងឧទ្យានជាតិកែប

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញសេចក្តីជូនដំណឹងលេខ ១០៧៣ សជណ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញភាពចាំបាច់នៃការគ្រប់គ្រងតំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និងកែប

## សំរេច

ប្រការ ១ : តែងតាំងគណៈកម្មការដោះស្រាយបាតុភាពនៅក្នុងតំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និងក្រុងកែប ដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម ឆាន់ សាផាន រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាប្រធាន